# សុន្ទរកថា

## អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

## ឧបនាយករដ្ឋមន្ត្រី, រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈ

## ថ្លែងក្នុងពិធី

## «ប្រកាសពង្រីកការប្រើប្រាស់មុខងាររបស់ FMIS, ពង្រីកការអនុវត្តនីតិវិធីតាម FMIS ទាំងស្រុង, ពង្រីកការប្រើប្រាស់ FMIS Portal ជំនាន់ទី ១ នៅរដ្ឋបាលថ្នាក់ក្រោមជាតិ និង ការប្រកាសដាក់ឱ្យអនុវត្តគម្រោងរៀបចំមុខងារគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ នៅក្រសួងចំនួន ៥ ដំបូង»

សាលាជាតិគយ, ថ្ងៃពុធ ទី ២២ ខែ មីនា ឆ្នាំ ២០២៣

- ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, ថ្នាក់ដឹកនាំ, តំណាងក្រសួង-ស្ថាប័ន និង ដៃគូអភិវឌ្ឍន៍;
- លោក Bryan Fornari ទីប្រឹក្សា-ប្រធានកិច្ចសហប្រតិបត្តិការប្រតិភូនៃសហភាពអឺរ៉ុប ប្រចាំព្រះរាជាណាចក្រកម្ពុជា;
- ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, សមាជិក, សមាជិកានៃអង្គពិធី, ជាទីមេត្រី!

ថ្ងៃនេះ, ខ្ញុំមានសេចក្តីសោមនស្សជាអនេក ដោយបានមកចូលរួមជាអធិបតី ក្នុងពិធី «ប្រកាសពង្រីកការប្រើប្រាស់មុខងាររបស់ FMIS, ពង្រីកការអនុវត្តនីតិវិធីតាម FMIS ទាំងស្រុង, ពង្រីកការប្រើប្រាស់ FMIS Portal ជំនាន់ទី ១ នៅរដ្ឋបាលថ្នាក់ក្រោមជាតិ និង ការប្រកាសដាក់ឱ្យអនុវត្តគម្រោងរៀបចំមុខងារគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ នៅក្រសួងចំនួន ៥ ដំបូង» ។ ខ្ញុំសូមសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅ ចំពោះវត្តមាន ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, ជាថ្នាក់ដឹកនាំ, មន្ត្រីរាជការ, តំណាងដៃគូអភិវឌ្ឍន៍, ភ្ញៀវជាតិ និង អន្តរជាតិ,

ដែលបានចូលរួមក្នុងពិធីនាថ្ងៃនេះ, ទាំងនៅទីនេះផ្ទាល់ និង នៅតាមប្រព័ន្ធវីដេអូ អនឡាញពីចម្ងាយ ។

ខ្ញុំសូមថ្លែងអំណរគុណ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី, រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, និង ជាប្រធានក្រុមការងារគ្រប់គ្រងគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ FMIS, ដែលបានផ្តល់នូវរបាយការណ៍យ៉ាងក្បោះក្បាយ ដោយរៀបរាប់អំពីទិដ្ឋភាពទូទៅនៃការអនុវត្តគម្រោង FMIS និង ដំណើរការនៃការរៀបចំ, អភិវឌ្ឍ និង ដាក់ឱ្យអនុវត្តជាជំហានៗ នូវមុខងារនីមួយៗរបស់ FMIS រួមជាមួយនឹង FMIS Portal ជំនាន់ទី ១ និង នីតិវិធីអនុវត្តការងារតាមប្រព័ន្ធទាំងស្រុង ដែលមានវិសាលភាពកាន់តែធំឡើងៗជាលំដាប់, រីកសាយភាយនៅគ្រប់ទីកន្លែងសំខាន់ៗនៅទូទាំងប្រទេស រហូតមកដល់ថ្ងៃនេះ និង កំពុងតែបន្តឆ្ពោះទៅកាន់ទីតាំងដែលនៅសេសសល់ផ្សេងទៀត នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

បន្ទាប់ពីបានស្តាប់របាយការណ៍របស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប** រួច, ខ្ញុំពិតជាមានក្តីរំភើបជាពន់ពេក ដែលបានឃើញនូវសមិទ្ធផលដ៏ច្រើនសន្ធឹកសន្ធាប់ លេចចេញឡើង ពីការអនុវត្តគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលបានផ្តល់នូវគុណតម្លៃយ៉ាងពិតប្រាកដ សម្រាប់ប្រទេសជាតិ, ជាពិសេស បានចូលរួមចំណែកយ៉ាងធំធេង ក្នុងដំណើរការនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជា ។ ពិតណាស់ថា សមិទ្ធផលទាំងនេះ **មិនមែនកើតចេញដោយភ្លាមៗ និង ងាយៗនោះទេ** ពោលគឺកើតចេញពីការប្តេជ្ញាចិត្តខ្ពស់ និង កិច្ចខិតខំប្រឹងប្រែងយ៉ាងមោះមុត និង មិនរាថយ របស់ថ្នាក់ដឹកនាំ និង មន្ត្រីគ្រប់ជាន់ថ្នាក់ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, ជាពិសេស ក្រុមការងារគ្រប់គ្រងគម្រោង FMIS និង ការចូលរួមគាំទ្រយ៉ាងសស្រាក់សស្រាំ ពីគ្រប់តួអង្គពាក់ព័ន្ធនៅតាមក្រសួង-ស្ថាប័ន ស្របតាមឆន្ទៈនយោបាយ និង ការតម្រង់ទិសយ៉ាងម៉ឺងម៉ាត់ និង ឈ្លាសវៃបំផុតរបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា គឺ **សម្តេច-អគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលជាអគ្គមគ្គុទេសក៍ឯកដ៏ឆ្នើមបំផុតរបស់កម្ពុជា** ។

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាកម្មវិធីគោលនយោបាយអាទិភាពមួយរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលមានចក្ខុវិស័យប្រែក្លាយប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជា ឆ្ពោះទៅកាន់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលផ្តោតលើលទ្ធផល ឬ សមិទ្ធកម្ម និង វិមជ្ឈការ ស្របតាមស្តង់ដា និង ឧត្តមានុវត្តន៍អន្តរជាតិ ។ FMIS គឺជាឧបករណ៍ស្នូល ដែល

មិនអាចខ្វះបាន សម្រាប់ជួយគាំទ្រ និង ជំរុញដល់ការសម្រេចបាន នូវគោលដៅនៃដំណាក់-កាលនីមួយៗរបស់កម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ រួមមាន ការបង្កើនភាពជឿទុកចិត្តនៃថវិកា, ការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ, ការបង្កើនការផ្សារភ្ជាប់ថវិកាទៅនឹងគោល-នយោបាយ និង ការបង្កើនគណនេយ្យភាពសមិទ្ធកម្ម ព្រមទាំងជួយក្នុងការបង្កើនប្រសិទ្ធភាព, តម្លាភាព និង គណនេយ្យភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជារួម ។

អស់រយៈពេលជាង ៧ ឆ្នាំនៃការដាក់ឱ្យដំណើរការ និង ការពង្រីកការប្រើប្រាស់ FMIS ជាបន្តបន្ទាប់ រហូតមកដល់បច្ចុប្បន្ននេះ, ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ពិតជាបានឆ្លងកាត់នូវបទពិសោធន៍ពិតប្រាកដ និង ជាក់ស្តែង ព្រមទាំងទទួលបាននូវមេរៀនជាច្រើន នៅក្នុងដំណើរការអនុវត្តគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង កំពុងបន្តដំណើរទៅមុខឥតឈប់ ឆ្ពោះទៅកាន់គោលដៅនៃការ-ពង្រីកការប្រើប្រាស់ FMIS ទៅដល់គ្រប់តួអង្គ និង គ្រប់ទិសទី ដែលជាការដ្ឋានអនុវត្ត និង គ្រប់គ្រងកិច្ចការងារហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជា ។

### *ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី!*

ខ្ញុំសូមគូសរំលេចដោយសង្ខេប អំពីដំណើរនៃការដាក់ឱ្យប្រើប្រាស់ FMIS, ដែលដំបូងឡើយ FMIS ត្រូវបានដាក់ឱ្យប្រើប្រាស់តែនៅតាមអគ្គនាយកដ្ឋានគន្លឹះៗផ្ទៃក្នុងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង មានតែមុខងារស្នូលប៉ុណ្ណោះ ពោលគឺមុខងារពាក់ព័ន្ធនឹងការអនុវត្តថវិកា និង កិច្ចការងាររតនាគារ ។ ដំហានដំបូងនេះ បានដាក់បន្ទុកបន្ថែមដល់មន្ត្រីនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង រតនាគាររាជធានី-ខេត្ត ដែលត្រូវបន្តអនុវត្តការងារជាមួយឯកសារជាក្រដាសដដែលផង និង តម្រូវឱ្យកត់ត្រាប្រតិបត្តិការរបស់គ្រប់ក្រសួង-ស្ថាប័ននៅថ្នាក់កណ្តាល និង គ្រប់អង្គភាពនៅថ្នាក់មូលដ្ឋាន បញ្ចូលទៅក្នុងប្រព័ន្ធផង ដែលជាជំហានដ៏លំបាក សម្រាប់ការជំរុញការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ។

ចំណែកឯជំហានទី ២ បានផ្តោតលើការពង្រីកការប្រើប្រាស់ FMIS ទៅកាន់គ្រប់ក្រសួង-ស្ថាប័ន និង មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដោយជំហាននេះ បានកាត់បន្ថយបន្ទុកខ្លះ សម្រាប់មន្ត្រីរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង រតនាគាររាជធានី-ខេត្ត ប៉ុន្តែត្រូវបង្កើនបន្ទុកខ្លះ ចំពោះមន្ត្រីនៃក្រសួង-ស្ថាប័ន និង មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជំនួសវិញ ។ នៅក្នុងជំហានទី ២ នេះ, ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក៏បានគិតគូររៀបចំនូវយុទ្ធសាស្ត្រសម្រាប់ការតម្រឹមនីតិវិធីអនុវត្តការងារតាម FMIS ដោយដាក់គោលដៅ បញ្ឈប់រំហូរនៃការប្រើប្រាស់ឯកសារជាក្រដាស ជំនួសដោយរំហូរការងារ តាមប្រព័ន្ធទាំងស្រុងវិញ

និង បានសាកល្បងដោយជោគជ័យ សម្រាប់នីតិវិធីទូទាត់ចំណាយបៀវត្ស, ចំណាយទឹក-ភ្លើង និង ចំណាយបន្ទុកបុគ្គលិកមួយចំនួនទៀត នៅក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងចំនួន ៧ ក្នុងឆ្នាំ ២០២០ ។

ឆ្លងកាត់ជំហានទាំង ២ ខាងលើ, យើងទទួលបាននូវមូលដ្ឋានគ្រឹះដ៏សំខាន់ សម្រាប់ការតម្រង់ទិសបន្ត នៅក្នុងជំហានទី ៣ ដែលបានចាប់ផ្តើមនៅក្នុងឆ្នាំ ២០២១ និង គ្រោងបញ្ចប់ក្នុងឆ្នាំ ២០២៥ ដើម្បីទាញប្រយោជន៍ឱ្យបានជាអតិបរិមា ពីប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលយើងកំពុងប្រើប្រាស់ស្រាប់ ។ ឥឡូវនេះ, យើងកំពុងតែស្ថិតនៅពាក់កណ្តាលផ្លូវនៃជំហានទី ៣ នៅក្នុងការអនុវត្តគម្រោង FMIS, ដែលផ្តោតលើគោលដៅធំចំនួន ៣ គឺ៖

**១-ការពង្រីកការដ្ឋានប្រើប្រាស់ FMIS ដែលនៅសេសសល់** ដូចជា អង្គភាពថវិកាបន្ថែមថ្មីនៅថ្នាក់កណ្តាល, អង្គភាពថវិកានៅថ្នាក់មូលដ្ឋាន, គ្រឹះស្ថានសាធារណៈមានលក្ខណៈរដ្ឋបាល ជាដើម ។

**២-ការអភិវឌ្ឍ និង ការពង្រីកការប្រើប្រាស់មុខងារថ្មីៗបន្ថែមទៀតរបស់ FMIS** រួមមាន មុខងាររៀបចំផែនការថវិកា, មុខងារលទ្ធកម្មពេញលេញ, មុខងារគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ជាដើម ។

**៣-ការបន្តធ្វើឌីជីថលូបនីយកម្មទៅលើនីតិវិធីអនុវត្តការងារការទូទាត់ និង ការផ្លាស់ប្តូរទិន្នន័យតាមប្រព័ន្ធអេឡិចត្រូនិក** ដែលនឹងកាត់បន្ថយការប្រើប្រាស់ឯកសារជាក្រដាស ឱ្យបានជាអតិបរមា; ក្នុងនោះ, រួមមាន ការបន្តពង្រីកវិសាលភាពនៃការតម្រឹមនីតិវិធីអនុវត្តការងារតាម FMIS ទាំងស្រុង, ការពង្រីកការប្រើប្រាស់ FMIS Portal ជំនាន់ទី ១ សម្រាប់រដ្ឋបាលក្រុង-ស្រុក និង ឃុំ-សង្កាត់ និង អង្គភាពចំណាយផ្សេងទៀត ជាដើម ជាមួយនឹងការបន្តអភិវឌ្ឍមុខងារថ្មីៗ និង ការកែលម្អប្រព័ន្ធដែលមានស្រាប់ទាំងអស់ ជាបន្តបន្ទាប់ឱ្យកាន់តែមានលក្ខណៈងាយស្រួលសម្រាប់ការប្រើប្រាស់ និង មានសុវត្ថិភាពខ្ពស់ ព្រមទាំងការបន្តអភិវឌ្ឍកម្មវិធីនានា ដើម្បីអាចប្រើប្រាស់បាននៅលើទូរសព្ទដៃ និង ឧបករណ៍ឆ្លាតវៃនានា ។

ការងារទាំង ៣ ខាងលើនេះ គឺជាអាទិភាពគន្លឹះមួយ ក្នុងចំណោមអាទិភាពគន្លឹះទាំង ៥ ដែលត្រូវអនុវត្តក្នុងដំណាក់កាលទី ៤ នៃកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ ដូចដែលត្រូវបានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការដោយ **សម្តេចអគ្គសេនាមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** កាលពីថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០២៣ ពោលគឺ «**ការពង្រីកវិសាលភាព និង ការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តប្រព័ន្ធ**

**បច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS), ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ**» ។

***ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី!***

ជាក់ស្តែង, ពេលនេះ, ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, តាមរយៈក្រុមការងារគ្រប់គ្រងគម្រោង FMIS សម្រេចបាននូវលទ្ធផលគោលដៅធំៗចំនួន ៦ រួចជាស្រេច ក្នុងការឆ្លើយតបទៅនឹងផែនការ ដែលត្រូវបានដាក់ចេញសម្រាប់ឆ្នាំ ២០២៣ ក្នុងក្របខណ្ឌផែនការរួម ដំណាក់កាលទី ៤ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងផែនការពង្រីកការអនុវត្តគម្រោង FMIS ជំហានទី ៣ ដែលខ្ញុំនឹងរៀបរាប់ម្តងមួយ ដូចខាងក្រោម៖

**ទី១).**បញ្ចប់ការរៀបចំ និង អភិវឌ្ឍប្រព័ន្ធ ដើម្បីដាក់ឱ្យ**អនុវត្តនីតិវិធីចំណាយថវិកាចរន្តគ្រប់មុខសញ្ញាតាម FMIS ទាំងស្រុង សម្រាប់ក្រសួង-ស្ថាប័នចំនួន ៥** គឺ ៖ ១-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា; ២-អាជ្ញាធរសវនកម្មជាតិ; ៣-ក្រសួងធម្មការ និង សាសនា; ៤-ក្រសួងរ៉ែ និង ថាមពល និង ៥-ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍; បន្ទាប់ពីបានអនុវត្តដោយជោគជ័យ នូវនីតិវិធីនេះនៅក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងបរិស្ថាន និង ផ្អែកតាមផែនការយុទ្ធសាស្ត្រតម្រង់ទិសនីតិវិធីអនុវត្តការងារតាម FMIS ២០២០-២០២៥ ។ ក្នុងពេលឆាប់ៗនេះ, ការអនុវត្តនីតិវិធីតាម FMIS ទាំងស្រុង នឹងត្រូវបានដាក់ឱ្យអនុវត្តនៅក្រសួងយុត្តិធម៌ផងដែរ ។

**ទី២).**បញ្ចប់ការរៀបចំ និង អភិវឌ្ឍប្រព័ន្ធ ដើម្បី**ដាក់ឱ្យអនុវត្តនីតិវិធីចំណាយថវិកាទូទាត់សេវាបំណុលក្នុងជំពូក ៥០ និង ៦៦ តាម FMIS ទាំងស្រុង** នៅក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលអនុវត្តដោយអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និង គ្រប់គ្រងបំណុល និង អគ្គនាយកដ្ឋានរតនាគារជាតិ ដែលនីតិវិធីនេះមិនត្រូវបានគ្រោងនៅក្នុងផែនការឆ្នាំ ២០២៣ ទេ ប៉ុន្តែតបតាមការស្នើសុំ និង ការស្ម័គ្រចិត្តរបស់អង្គភាពអនុវត្តផ្ទាល់ ។

**ទី៣).**បញ្ចប់ការរៀបចំ និង អភិវឌ្ឍប្រព័ន្ធ ដើម្បី**ដាក់ឱ្យប្រើប្រាស់កម្មវិធី FMIS Portal ទៅកាន់រដ្ឋបាលក្រុង-ស្រុក និង ឃុំ-សង្កាត់ សរុបចំនួន ៥៤២ បន្ថែម** ដែលក្នុងនោះរួមមាន រដ្ឋបាលក្រុងចំនួន ៦, រដ្ឋបាលស្រុកចំនួន ៦១, រដ្ឋបាលសង្កាត់ចំនួន ២៨ និងរដ្ឋបាលឃុំចំនួន ៤៤៧ នៃខេត្តចំនួន ២២ ។ ក្រុមការងារបច្ចេកទេស ក៏បានអភិវឌ្ឍបន្ថែមនូវមុខងារ និង ឧបករណ៍ថ្មីជូនដល់អ្នកប្រើប្រាស់ ឱ្យកាន់តែមានភាពងាយស្រួល ស្របតាម

ស្ថានភាពនៃសមត្ថភាពរបស់អ្នកប្រើប្រាស់ផង និង សេវាទូរគមនាគមន៍នៅតាមបណ្ដាឃុំឆ្ងាយៗផង ។ ខ្ញុំសូមរំលឹកផងដែរថា កម្មវិធី FMIS Portal ជំនាន់ទី ១ នេះ ធ្លាប់ត្រូវបានដាក់ឱ្យប្រើប្រាស់ដោយជោគជ័យ នៅរដ្ឋបាលស្រុក និង រដ្ឋបាលឃុំ សរុបចំនួន ២៦០ រួចមកហើយ ក្នុងជំហានទី ១ កាលពីខែឧសភា ឆ្នាំ ២០២២ កន្លងទៅ ។

**ទី៤).**បញ្ចប់ការរៀបចំ និង អភិវឌ្ឍប្រព័ន្ធ ដើម្បី**ដាក់ឱ្យប្រើប្រាស់មុខងារស្នូលនៃ FMIS ទៅកាន់អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញចំនួន ១០ បន្ថែមថ្មី**, ក្នុងនោះរួមមាន ៖ អង្គភាពថវិកាចំនួន ៦ ស្ថិតក្នុងក្របខណ្ឌនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ គឺ ៖ ១-អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ, ២-និយ័តករធានារ៉ាប់រងកម្ពុជា, ៣-និយ័តករបរធនបាលកិច្ច, ៤-និយ័តករអាជីវកម្មអចលនវត្ថុ និង បញ្ចាំ, ៥-អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា, និង ៦-អង្គភាពសវនកម្មផ្ទៃក្នុងនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ; និង អង្គភាពថវិកាចំនួន ៤ ទៀតស្ថិតក្នុងក្របខណ្ឌនៃក្រសួងមហាផ្ទៃ គឺ ៖ ១-គណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម, ២-អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន, ៣-អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក, និង ៤-អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។ លើសពីនេះ, ផ្អែកតាមបាយ-ការណ៍របស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប** អំបាញ់មិញ, មុខងារស្នូលរបស់ FMIS ត្រូវបានដាក់ឱ្យប្រើប្រាស់នៅការដ្ឋានចំនួន ១៥៦ រួចមកហើយ នៅទូទាំងប្រទេសរាប់ចាប់តាំងពីជំហានទី ១ រហូតដល់ដំណាច់ឆ្នាំ ២០២២ និង បានភ្ជាប់សន្ធានកម្មជាមួយប្រព័ន្ធផ្សេងៗចំនួន ១៦ ផងដែរ ។

**ទី៥).**បញ្ចប់ការរៀបចំ និង អភិវឌ្ឍប្រព័ន្ធ ដើម្បី**ដាក់ឱ្យប្រើប្រាស់មុខងាររៀបចំផែនការថវិកា ទៅកាន់ក្រសួង-ស្ថាប័នចំនួន ១២, អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ ថ្នាក់កណ្ដាលចំនួន ១៧ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, ព្រមទាំងមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ទាំង ២៥ ដែលជាអង្គភាពថវិកាថ្នាក់មូលដ្ឋានរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ** ។ ក្រសួង-ស្ថាប័នទាំង ១២ រួមមាន ៖ ១-អាជ្ញាធរសវនកម្មជាតិ, ២-អគ្គ-លេខាធិការដ្ឋានព្រឹទ្ធសភា, ៣-អគ្គលេខាធិការដ្ឋានរដ្ឋសភា, ៤-ក្រសួងធនធានទឹក និង ឧតុនិយម, ៥-ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ, ៦-ក្រសួងពាណិជ្ជកម្ម, ៧-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា, ៨-ក្រសួងទេសចរណ៍, ៩-រដ្ឋ-លេខាធិការដ្ឋានអាកាសចរស៊ីវិល, ១០-ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍, ១១-តុលាការ

កំពូល, និង ១២-សាលាឧទ្ធរណ៍ ។ ជាមួយគ្នានេះ, ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងបរិស្ថាន ត្រូវធ្វើការសាកល្បងអនុវត្តការចរចាថវិកាតាមប្រព័ន្ធនៅក្នុងឆ្នាំ ២០២៣ នេះ នៅក្នុងមុខងាររៀបចំផែនការថវិកា ដើម្បីពិនិត្យលទ្ធភាពពង្រីកទៅកាន់ក្រសួង-ស្ថាប័នផ្សេងទៀត ។ ខ្ញុំសូមជម្រាបថា មុខងាររៀបចំផែនការថវិកានេះ ត្រូវបានដាក់ឱ្យប្រើប្រាស់រួចហើយ នៅក្រសួង-ស្ថាប័នចំនួន ១៣ គិតត្រឹមដំណាច់ឆ្នាំ ២០២២ ។

**ទី៦).**បញ្ចប់ការរៀបចំ និង អភិវឌ្ឍប្រព័ន្ធ ដើម្បី**ដាក់ឱ្យប្រើប្រាស់មុខងារលទ្ធកម្មពេញលេញ ទៅកាន់អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ នៅថ្នាក់កណ្តាលចំនួន ២០** ក្នុងនោះ អង្គភាពថវិកាថ្នាក់កណ្តាលនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ចំនួន ១៦ និង អង្គភាពថវិកាថ្នាក់កណ្តាលចំនួន ៤ នៃក្រសួងមហាផ្ទៃ រួមទាំង **មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុរាជធានី-ខេត្តទាំង ២៥** ផងដែរ ។ មុខងាររៀបចំលទ្ធកម្មពេញលេញនេះ ត្រូវបានដាក់ឱ្យប្រើប្រាស់នៅគ្រប់ក្រសួង-ស្ថាប័នរួចហើយ នៅថ្នាក់កណ្តាលគិតត្រឹមដំណាច់ឆ្នាំ ២០២២ ។

***ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី !***

សមិទ្ធផលដ៏ច្រើនទាំងនេះ ពិតជាធ្វើឱ្យយើងទាំងអស់គ្នា មានកម្លាំងចិត្តយ៉ាងមុតមាំ ដើម្បីបន្តដំណើរទៅមុខ ក្នុងស្មារតីប្រឹងប្រែងឥតឈប់ និង ប្រុងប្រយ័ត្នជានិច្ច នៅក្នុងបុព្វហេតុបម្រើជាតិមាតុភូមិ ។ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នៅតែបន្តមានមហិច្ឆតា ពង្រីកវិសាលភាពនៃការប្រើប្រាស់ FMIS រហូតដល់អង្គភាពអនុវត្តថវិកា និង អង្គភាពចំណាយថវិការដ្ឋ នៅគ្រប់ទិសទីនៅទូទាំងប្រទេស, ជាពិសេស បន្តធ្វើបរិវត្តកម្មឌីជីថលថ្មីៗបន្ថែមទៀត ដោយផ្សារភ្ជាប់ទៅនឹងមុខងារដែលមានស្រាប់ និង មុខងារ ដែលនឹងត្រូវអភិវឌ្ឍថ្មីរបស់ FMIS រួមទាំងការប្រែក្លាយនីតិវិធីអនុវត្តការងារដោយដៃបច្ចុប្បន្ន និង ជាក្រដាស ទៅជានីតិវិធីតាមបែបឌីជីថលទាំងស្រុង ។ ទន្ទឹមនេះ, ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានការប្តេជ្ញាចិត្តយ៉ាងម៉ឺងម៉ាត់ ក្នុងការធ្វើជាគំរូអនុវត្តមុនគេ នៅក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សម្រាប់ការផ្លាស់ប្តូរនានា ក្នុងការអនុវត្តការងារថ្មី សម្រាប់ជាពិសោធន៍មុននឹងឈានទៅជំរុញការអនុវត្តនៅតាមក្រសួង-ស្ថាប័នផ្សេងទៀត ។

ការពង្រីកវិសាលភាពនៃការប្រើប្រាស់ FMIS ជាមួយនឹងការពង្រីកការអនុវត្តនីតិវិធីអនុវត្តការងារតាម FMIS ទាំងស្រុង គឺជាចំណែកនៃគន្លងការងារថ្មីរបស់រាជរដ្ឋាភិបាលផ្អែកតាមក្របខណ្ឌគោលនយោបាយរដ្ឋាភិបាលឌីជីថល ។ ដូច្នេះ, **មន្ត្រីរាជការត្រូវត្រៀមលក្ខណៈឱ្យបានរួចរាល់ ក្នុងការរៀនសូត្របន្ថែម និង ចាប់យកឱ្យបាននូវការផ្លាស់ប្តូរ របៀបធ្វើ**

ការងារថ្មី, បង្កើនភាពស៊ាំឱ្យបានលឿន, តាមឱ្យទាន់កាលៈទេសៈនៃការវិវឌ្ឍសង្គម និង សេដ្ឋកិច្ចឌីជីថល ។

ខ្ញុំសូមរម្លឹកនូវឱវាទានុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលតែងដាស់តឿនយើងទាំងអស់គ្នាជារឿយៗថា **«កែទម្រង់-រស់, មិនកែទម្រង់-ស្លាប់»**; **«គ្មានលទ្ធផលណាដែលបានមកដោយមិនមានការបង់ថ្លៃនោះទេ ហើយក៏គ្មានការកែទម្រង់ណាដែលសម្រេចបានដោយមិនមានការលះបង់នោះដែរ»** ។ ក្នុងន័យនេះ, ខ្ញុំសង្ឃឹមថា ថ្នាក់ដឹកនាំ និង មន្ត្រីគ្រប់លំដាប់ថ្នាក់ ដែលមានតួនាទី និង ភារកិច្ច ក្នុងការបំពេញកិច្ចការគ្រប់គ្រងថវិកា និង ហិរញ្ញវត្ថុសាធារណៈ នឹងប្រឹងប្រែងលះបង់នូវប្រយោជន៍ស្ទួនតួកន្លងមក ហើយបែមកគិតគូរប្តេជ្ញាចិត្ត ឱ្យបានមុតមាំតាមគំរូលះបង់ និង ប្រកបដោយវីរភាពដ៏អង់អាចរបស់ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** ដែលតែងតែតម្កល់ប្រយោជន៍ជាតិជាធំ ។ ខ្ញុំក៏សូមលើកទឹកចិត្តដល់មន្ត្រីរបស់យើង ឱ្យផ្លាស់ប្តូរផ្នត់គំនិត មកទទួលយកនូវបរិបទថ្មី នៃការផ្លាស់ប្តូររបៀបរបបបំពេញការងារ ព្រមទាំងខិតខំបំពេញភារកិច្ចរបស់ខ្លួន ឱ្យបានត្រឹមត្រូវ ប្រកបដោយវិជ្ជាជីវៈ ដោយគិតពីប្រសិទ្ធភាពនៃការប្រើប្រាស់ថវិកាជាតិ និង **«តម្លៃនៃលុយ»** ដើម្បីលើកកម្ពស់គុណភាព និង ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ ឱ្យបានកាន់តែប្រសើរឡើងជាលំដាប់ ។

ឆ្លៀតឱកាសនេះ, ខ្ញុំសូមវាយតម្លៃខ្ពស់ ចំពោះការខិតខំរបស់ក្រុមការងារគ្រប់គ្រងគម្រោង FMIS ដែលដឹកនាំដោយ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប**, លេខាធិការដ្ឋាន និង អគ្គនាយកដ្ឋាននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលបានគាំទ្រ និង ចូលរួមសហការគ្នាជាធ្លុងមួយនាពេលកន្លងមក ក្នុងការសម្រេចបាននូវសមិទ្ធផលជាច្រើន ដូចបានរៀបរាប់ខាងលើ ។ ខ្ញុំក៏សូមថ្លែងអំណរគុណដល់គ្រប់ភាគីពាក់ព័ន្ធនៃក្រសួង-ស្ថាប័ន និង អង្គភាពនៅថ្នាក់មូលដ្ឋាន, ជាពិសេស ដៃគូអភិវឌ្ឍន៍ ដែលបានចូលរួមគាំទ្រនាពេលកន្លងមក, ទាំងជាបច្ចេកទេស និង ជាហិរញ្ញប្បទាន ។ ខ្ញុំសូមលើកទឹកចិត្តដល់គ្រប់តួអង្គពាក់ព័ន្ធទាំងអស់ ឱ្យបន្តកិច្ចសហប្រតិបត្តិការជិតស្និទ្ធបន្តទៀត ដោយឥតបង្អង់ ដើម្បីរួមគ្នានាំកម្ពុជាឈានឆ្ពោះទៅរកភាពរីកចម្រើន និង វិបុលភាព នៅក្រោមម្លប់ដ៏ត្រជាក់នៃសុខសន្តិភាព ។

ជាទីបញ្ចប់, ខ្ញុំសូមប្រសិទ្ធពរជូនឯកឧត្តម, លោកជំទាវ, លោក, លោកស្រីទាំងអស់ ប្រកបដោយសុខភាពល្អបរិបូរណ៍, មានសុភមង្គលក្នុងក្រុមគ្រួសារ និង សម្រេចបាននូវជោគជ័យក្នុងគ្រប់ភារកិច្ច ។

***ខ្ញុំសូមប្រកាស៖***

១). ដាក់ឱ្យអនុវត្តនីតិវិធីចំណាយថវិកាចរន្តគ្រប់មុខសញ្ញា តាម FMIS ទាំងស្រុង សម្រាប់ក្រសួង-ស្ថាប័នចំនួន ៥ បន្ថែម;

២). ដាក់ឱ្យអនុវត្តនីតិវិធីចំណាយថវិកាទូទាត់សេវាបំណុល ក្នុងជំពូក ៥០ និង ៦៦ តាម FMIS ទាំងស្រុង នៅក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ;

៣). ដាក់ឱ្យប្រើប្រាស់កម្មវិធី FMIS Portal ជំនាន់ទី ១ ទៅកាន់រដ្ឋបាលក្រុង-ស្រុក និង ឃុំ-សង្កាត់ សរុបចំនួន ៥៤២ បន្ថែម;

៤). ដាក់ឱ្យប្រើប្រាស់មុខងារស្នូលនៃ FMIS ទៅកាន់អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញចំនួន ១០ បន្ថែមថ្មី;

៥). ដាក់ឱ្យប្រើប្រាស់មុខងាររៀបចំផែនការថវិកា ទៅកាន់ក្រសួង-ស្ថាប័ន ចំនួន ១២, អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញថ្នាក់កណ្ដាល ចំនួន ១៧, និង មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុទាំង ២៥;

៦). ដាក់ឱ្យប្រើប្រាស់មុខងារលទ្ធកម្មពេញលេញ ទៅកាន់អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញនៅថ្នាក់កណ្ដាល ចំនួន ២០ និង មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ទាំង ២៥ និង

៧). ប្រកាសដាក់ឱ្យអនុវត្តគម្រោង **មុខងារគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ** នៅក្នុង FMIS ជាមួយក្រសួង-ស្ថាប័នចំនួន ៥ គឺ **១.**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ; ២.ក្រសួងបរិស្ថាន; ៣.ក្រសួងសុខាភិបាល; ៤.ក្រសួងមហាផ្ទៃ; និង ៥.ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ; **ចាប់ពីពេលនេះតទៅ** ។

៨). ជាមួយគ្នានេះ, ខ្ញុំក៏សូមប្រកាសជាមុនផងដែរ នូវការដាក់ឱ្យអនុវត្តនីតិវិធីចំណាយថវិកាចរន្តគ្រប់មុខសញ្ញាតាម FMIS ទាំងស្រុង សម្រាប់ក្រសួងយុត្តិធម៌ នៅក្នុងខែមិថុនា ២០២៣ តទៅ ៕

***សូមអរគុណ !***